ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

******

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ប្រ.ក/លេខ ០៦.០៨៤/០៨ គ.ជ.ប.អគ្គ.ពស

ភ្នំពេញ ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០០៨

# គ.ជ.ប ផ្សព្វផ្សាយពីវិធីចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោត

នៅថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០០៨ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានរៀបចំកិច្ចប្រជុំដើម្បីផ្សព្វផ្សាយអំពីដំណើរការចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោតដល់គណបក្សនយោបាយ និងអង្គការមិនមែនរដ្ឋាភិបាល។ ការចែកប័ណ្ណព័ត៌មាននេះចាប់ផ្តើមពីថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០០៨។

លោកជំទាវ កុយ វ៉េត សមាជិកា គ.ជ.ប និងជាប្រធានដឹកនាំកិច្ចប្រជុំបានមានប្រសាសន៍ថា ប័ណ្ណព័ត៌មាននេះត្រូវបានផ្ទេរទិន្នន័យអ្នកបោះឆ្នោតម្នាក់ៗ (លេខរៀង ឈ្មោះ ថ្ងៃខែឆ្នាំកំណើត លេខកូដការិយាល័យបោះឆ្នោត ទីតាំងការិយាល័យបោះឆ្នោត...) ដែលមាននៅក្នុងបញ្ជីបោះឆ្នោតផ្លូវការ ទៅក្នុងប័ណ្ណព័ត៌មាននោះ ហើយប័ណ្ណព័ត៌មានអ្នកបោះឆ្នោតនេះនឹងត្រូវបានធ្វើការចែកជូនដល់អ្នកបោះឆ្នោត ចាប់ពីថ្ងៃទី៥ ខែមិថុនា រហូតដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៨។

ប័ណ្ណព័ត៌មានអ្នកបោះឆ្នោត ជាប័ណ្ណសម្រាប់ជូនព័ត៌មានដល់អ្នកបោះឆ្នោតឱ្យដឹងអំពីកាលបរិច្ឆេទ និង ពេលវេលានៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៤ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃអាទិត្យ ទី២៧ ខែកក្កដា ឆ្នាំ២០០៨ ដោយចាប់ផ្តើមពីម៉ោង៧:០០ព្រឹក រហូតដល់ម៉ោង៣:០០រសៀល ។ ទីតាំង និងលេខកូដការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ ដែលអ្នកត្រូវទៅបោះឆ្នោត ។ លេខរៀង ឈ្មោះ ទិន្នន័យពាក់ព័ន្ធនឹងសាមីខ្លួនក្នុងបញ្ជីបោះឆ្នោត ព្រមទាំងប្រភេទឯកសារបញ្ជាក់អត្តសញ្ញាណផ្លូវការសម្រាប់ប្រើប្រាស់ពេលបោះឆ្នោត ដែលក្នុងនោះគាត់ត្រូវប្រើឯកសារណាមួយដែលគាត់មាននៅពេលបោះឆ្នោត ។ ប៉ុន្តែគ្មានប័ណ្ណព័ត៌មានអ្នកបោះឆ្នោត ក៏អ្នកបោះឆ្នោតអាចបោះឆ្នោតបានដែរ ឱ្យតែមានឈ្មោះក្នុងបញ្ជីបោះឆ្នោត និងភ្ជាប់ទៅជាមួយនឹងឯកសារបញ្ជាក់អត្តសញ្ញាណណាមួយនៅថ្ងៃបោះឆ្នោត ។

លោកជំទាវបានបញ្ជាក់ថា សមាសភាពនៃក្រុមបែងចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោតមាន ÷

១- សមាជិក គឃ/សប ១រូប ជាប្រធាន

២- សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ មួយ ឬច្រើនរូប ជាសមាជិក

៣- តំណាងអង្គការមិនមែនរដ្ឋាភិបាលមួយ ឬច្រើនរូប ជាសមាជិក (ប្រសិនបើមាន)

៤- មេភូមិពាក់ព័ន្ធ ជាសមាជិក។

ពាក់ព័ន្ធនឹងក្រុមបែងចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោតនេះ ឯកឧត្តម គួយ ប៊ុនរឿន តំណាងគណបក្សសម រង្ស៊ី បាន ស្នើសុំនៅក្នុងកិច្ចប្រជុំនោះថា គ.ជ.ប គួរបញ្ចូលតំណាងគណបក្សនយោបាយដែលចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតជ្រើស តាំងតំណាងរាស្ត្រអាណត្តិទី៤ ឆ្នាំ២០០៨នេះ ទៅក្នុងសមាសភាពនៃក្រុមចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោតផង ដើម្បីឱ្យដំណើរ ការនៃការចែកប័ណ្ណព័ត៌មាននេះមានតម្លាភាព យុត្តិធម៌ និងគ្មានការរើសអើង។

លោក អ៊ិក គឹមហាន តំណាងគណបក្សប្រជាជនកម្ពុជាបានមានប្រសាសន៍ថា ប័ណ្ណព័ត៌មានអ្នកបោះឆ្នោតនេះមិនមែន ជាឯកសារផ្លូវការសម្រាប់ការបោះឆ្នោតនោះទេ អត្ថប្រយោជន៍របស់វា គឺជូនព័ត៌មានបោះឆ្នោតដល់អ្នកបោះឆ្នោតតែប៉ុណ្ណោះ បើគ្មានប័ណ្ណព័ត៌មាននេះ ក៏អ្នកបោះឆ្នោតអាចបោះឆ្នោតបានដែរ។

ឯកឧត្តម ទេព នីថា អគ្គលេខាធិការ គ.ជ.ប បានមានប្រសាសន៍ថា គ.ជ.ប មិនអាចបន្ថែមសមាសភាពក្រុមបែងចែក ប័ណ្ណព័ត៌មាន ក្រៅពីសមាសភាពដូចបានកំណត់នៅក្នុងសេចក្តីណែនាំលេខ ០១០ ស.ណ.ន ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៦ រវាង គ.ជ.ប និងក្រសួងមហាផ្ទៃនោះបានទេ ។ ឯកឧត្តមបានបញ្ជាក់ថា គណបក្សនយោបាយ ឬអង្គការមិនមែនរដ្ឋាភិបាលអាច បញ្ជូនភ្នាក់ងារដែលមាននៅតាមឃុំ សង្កាត់ ឱ្យចូលរួមសង្កេតមើលគ្រប់សកម្មភាពនៃដំណើរការចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោត នេះ។ ហើយបើសង្កេតមើលឃើញថា មានភាពមិនប្រក្រតីអាចប្តឹងតវ៉ា ឬជូនដំណឹងមក គឃ/កប ឬ គ.ជ.ប។ ឯកឧត្តមបាន បន្តទៀតថា គ.ជ.ប បានធ្វើការណែនាំដល់ គឃ/សប ឱ្យផ្សព្វផ្សាយដំណឹង និងអញ្ជើញតំណាងគណបក្សនយោបាយ និងអង្គការ មិនមែនរដ្ឋាភិបាលដែលមាននៅក្នុងឃុំ សង្កាត់ ឱ្យចូលរួមសង្កេតមើលអំពីដំណើរការនៃការចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោតនេះ។ ហើយចំពោះការចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោតលើកនេះ ខុសពីការចែកប័ណ្ណព័ត៌មាននៅពេលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់ អាណត្តិទី២កន្លងមក ពីព្រោះថា គ.ជ.ប ឱ្យក្រុមអ្នកចែកប័ណ្ណព័ត៌មានអញ្ជើញអ្នកបោះឆ្នោតនៅក្នុងភូមិមកប្រមូល ផ្តុំនៅកន្លែងណាមួយក្នុងភូមិ ទើបធ្វើការចែកប័ណ្ណព័ត៌មាននេះដល់ពួកគាត់ ។ ចំពោះប័ណ្ណព័ត៌មានដែលគ្មានអ្នកទទួលក្នុងពេល កំពុងចែកនោះ ក្រុមអ្នកចែកមិនអាចផ្ញើតាមរយៈនរណាម្នាក់បានឡើយ ។ ប៉ុន្តែក្រុមអ្នកចែកប័ណ្ណព័ត៌មានអាចផ្ញើប័ណ្ណព័ត៌មាន នេះតាមរយៈសាច់ញាតិ ឬតំណាងគ្រួសារ។

នៅក្នុងកិច្ចប្រជុំនេះដែរ តំណាងគណបក្សបានលើកឡើងថា តើ គ.ជ.ប អាចធានាបានទេ ក្រោយពីការបញ្ចប់នៃការ ចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោតនៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៨ នឹងមិនមានការបន្តចែកប័ណ្ណព័ត៌មាននេះនៅតាមភូមិ ឃុំ សង្កាត់បន្តទៀត។

ឯកឧត្តម ទេព នីថា បានបញ្ជាក់ថា ក្រោយបញ្ចប់នៃការចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោតនៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៨ ប័ណ្ណព័ត៌មានដែលនៅសល់ត្រូវរក្សាទុកនៅទីស្នាក់ការ គឃ/សប ហើយអ្នកបោះឆ្នោតអាចមកទទួលប័ណ្ណព័ត៌មាន នេះនៅ គឃ/សប រហូតដល់ថ្ងៃបោះឆ្នោត។ ប៉ុន្តែបើក្រុមណាមួយ ឬនរណាម្នាក់បន្តធ្វើសកម្មភាពចែកប័ណ្ណព័ត៌មាននេះហួស កាលបរិច្ឆេទខាងលើនៅតាមភូមិ គណបក្សនយោបាយអាចដាក់ពាក្យប្តឹងតាមនីតិវិធីមក គឃ/កប ឬ គ.ជ.ប។ ប៉ុន្តែសូមបញ្ជាក់ថា មានគណបក្សខ្លះគាត់ធ្វើប័ណ្ណព័ត៌មាននេះខ្លួនគាត់ រួចដើរចែកខ្លួនគាត់នៅតាមផ្ទះសមាជិកគណបក្សគាត់ នេះជាសិទ្ធិរបស់គាត់ ។